ភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៣

# សេចក្តីសំរេច លេខ ១៧ សសរ

## ស្តីពីការបង្កើតក្រុមការងារ សំរាប់ពិនិត្យ និង សម្របសម្រួល ការរៀបចំ និងការកែប្រែរចនាសម្ព័ន្ធរដ្ឋបាល

* * *

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសេចក្តីសំរេចចិត្តរបស់សភាតំណាងរាស្ត្រ របស់សភាតំណាងរាស្ត្រទាំង ១២០ រូប ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតំកល់ទុកនូវច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា
- យោងភារកិច្ច និង សមត្ថកិច្ចរបស់ ឧ ជ ន
- ដោយបានការអនុញ្ញាត ឯកឧត្តមប្រធាន រ.ជ.ប.ក ក្នុងការប្រគល់ភារកិច្ចពិសេសខ្លះៗ ជូនចំពោះទីប្រឹក្សារបស់ឯកឧត្តម
- បានឃើញការចាំបាច់លើការកែប្រែរចនាសម្ព័ន្ធរដ្ឋបាល

## សំរេច

ប្រការ ១ : បង្កើតក្រុមការងារមួយសំរាប់ពិនិត្យ និង សម្របសម្រួលការរៀបចំ និង ការកែប្រែរចនាសម្ព័ន្ធរដ្ឋបាល ក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តម ហង់ ជួន ទីប្រឹក្សាឯកឧត្តម សហប្រធាន ប្រធានក្រុមការងារ

២- ឯកឧត្តមជំទាវ ញូ ឈួន ទីប្រឹក្សាឯកឧត្តម សហប្រធាន ជាអនុប្រធានប្រចាំការ នៃ ក្រុមការងារ

៣- ឯកឧត្តម ម៉ម សូផាណា ទីប្រឹក្សាឯកឧត្តមសហប្រធាន ជាសមាជិក

៤- ឯកឧត្តម ប៊ុល ណាក់ ទីប្រឹក្សាឯកឧត្តមសហប្រធាន ជាសមាជិក

៥- លោក ប៊ុន អ៊ុយ ជាសមាជិក

៦- លោក សុខ សាមេន ជាសមាជិក

៧- លោកស្រី ស៊ុន សារី ជាសមាជិក

៨- លោក គ្រាញ់ ជ័យយោភិទ្ធី ជាសមាជិកអចិន្ត្រៃយ៍

៩- លោក ង៉ែម បូរី ជាសមាជិកអចិន្ត្រៃយ៍

១០- លោក មាស តិមសុភ័ក្ត្រ ជាលេខាធិការ

ប្រការ ២ : ក្រុមការងារសំរាប់ពិនិត្យ និង សំរបសំរួលការរៀបចំ និងការកែប្រែរចនាសម្ព័ន្ធរដ្ឋបាលមានភារកិច្ចដូចតទៅ ÷

១- ពិនិត្យពិចារណាក្នុងការរៀបចំ នូវ គំរោងរចនាសម្ព័ន្ធរដ្ឋបាល មួយសមស្រប ជូន រដ្ឋាភិបាល ។

២- ជួយរៀបចំ និង សំរបសំរួលគំរោងរចនាសម្ព័ន្ធ ក្នុងភារកិច្ចរបស់បណ្តាក្រសួង និង ស្ថាប័ននានាជាមួយនឹងក្រសួងមុខងារសាធារណៈសាមីក្រសួង និង ក្រសួងពាក់ព័ន្ធ អោយបានល្អិតល្អន់ត្រឹមត្រូវប្រពៃ ដើម្បីកំណត់អោយបានច្បាស់ នូវមុខសញ្ញា ភារកិច្ច និង សមត្ថកិច្ច ដើម្បីធានានូវ ការគ្រប់គ្រងរដ្ឋបាលប្រកបដោយគុណភាព និង ប្រសិទ្ធភាព ។

៣- ប្រមូលចងក្រងលទ្ធផលការងារតាមក្រសួងនិមួយ ៗ និង រៀបចំលិខិតបទដ្ឋានជូនគណៈដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈរដ្ឋមន្ត្រីដោយកែតំរូវបញ្ជាក់ពីលទ្ធផលនៃការកែ សំរួលទាំងឡាយណាដែលក្រុមជំនាញបានលើកឡើង ដើម្បីជាមូលដ្ឋានជូនសហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ពិនិត្យ និង សំរេចដាក់ថ្វាយសម្តេចព្រះមុខរដ្ឋ ។

៤- ក្រុមការងារនេះ មានភារកិច្ចទទួលរាល់សំណើទាំងពីបណ្តាក្រសួង ស្ថាប័ននានាដែល ស្នើសុំរចនាសម្ព័ន្ធរដ្ឋបាល ទន្ទឹមគ្នា និង ក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យសិក្សាផ្តល់យោបល់ ។ សេចក្តីព្រាង ក្រឹត្យ អនុក្រឹត្យ ដែលក្រុមការងារ បានទទួលពីក្រសួងនានាហើយ ត្រូវចាត់ការ ពិនិត្យពិភាក្សា ផ្តល់ និង ជូនឯកឧត្តមសហប្រធានទាំងពីរ អន្ត - ១០ ក្នុងរយៈ ២ ថ្ងៃ យ៉ាងយូរបំផុត ។ ក្រោយពីបានការឯកភាពពីរាជរដ្ឋាភិបាលជាតិបណ្តោះអាសន្នមក ក្រុមការងារនេះនឹងធ្វើក្រឹត្យ ដើម្បីដាក់ថ្វាយសម្តេច ព្រះប្រមុខរដ្ឋ ឡាយព្រះហស្តលេខា ។

ប្រការ ៣ : សមាជិកទាំងអស់នៃក្រុមការងារនេះ ត្រូវចូលរួមធ្វើការងារតាមការអញ្ជើញ និង ការ

ដែលនាំរបស់ប្រធាន ហើយរៀបចំកម្មវិធីទៀងទាត់ ដើម្បីជូនគណៈដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៤ : ក្រុមការងារនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកជំនាញ និង ទីប្រឹក្សា មានការ ៗ ដើម្បីមកពិភាក្សា អំពីរចនាសម្ព័ន្ធរដ្ឋបាល របស់ក្រសួង និងស្ថាប័ននីមួយ' តាមការចាំបាច់ នៃការណើដាក់ស្នើនីមួយៗ ។

ប្រការ ៥ : ក្រុមការងារនេះ នឹង ត្រូវរំសាយដោយស្វ័យប្រវត្តិ នៅពេលដែលរចនាសម្ព័ន្ធ រដ្ឋបាល ទូទាំងប្រទេស ត្រូវបានកែប្រែជាស្ថាពរហើយ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីមុខងារសាធារណៈ រដ្ឋមន្ត្រី និង ប្រធាន ក្រសួង ស្ថាប័ននានា និង សាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ។

ប្រការ ៧ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

សហប្រធាន ១ ៩ ៣

ចាត ឈង់

* * *

ភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ១៨ សសរ

### ស្តីពីការបង្កើតគណៈកម្មការទទួលអំណោយរៀបចំ អនាម័យ និង កែលំអសោភ័ណភាពទីក្រុងភ្នំពេញ

* * *

### រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេច ព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃ កម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ១៩៩៣
- បានឃើញតំរូវការចាំបាច់ នៃការងាររៀបចំ អនាម័យកែលំអទីក្រុងភ្នំពេញ